គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

ខុមហ្វ្រែល

## របាយការណ៍



# ការចូលរួមរបស់ស្ត្រី ក្នុងវិស័យនយោបាយ និង ការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៨

០៩

ខែកុម្ភៈ ឆ្នាំ២០

សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង :

លោក គល់ បញ្ញា
នាយកប្រតិបត្តិខុមហ្វ្រែល
ទូរសព្ទ : ០១២ ៩៤២ ០១៧
០២៣ ៨៨៤ ១៥០
**អ៊ីម៉ែល :** kpanha@online.com.kh

លោកស្រី សឺនកេត សិរីលក្ខណ៍
អ្នកសម្របសម្រួលផ្នែកអប់រំ និងយេនឌ័រខុមហ្វ្រែល
ទូរសព្ទ : ០១៧ ៧៧១ ២៧១
០២៣ ៨៨៤ ១៥០
**អ៊ីម៉ែល :** sereyleak@comfrel.org

# មាតិកា


**I.** សេចក្តីផ្តើម ........................................................................................................ ១

**II.** ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយក្នុងការបោះឆ្នោតតំណាងរាស្ត្រ ឆ្នាំ២០០៨........................ ៣

១. បេក្ខជនស្ត្រី និងតំណាងស្ត្រីជាប់ឆ្នោត ........................................................................ ៣

២. គោលនយោបាយរបស់គណបក្ស អំពី បញ្ហាស្ត្រី ............................................................ ៦

៣. សមាជិកស្ត្រីរបស់ គ.ជ.ប គធ/ខប គឃ/សប និងការិយាល័យបោះឆ្នោត .......................... ៩

៤. អ្នកសង្កេតការណ៍ជាស្ត្រី ........................................................................................ ៩

៥. អ្នកបោះឆ្នោតស្ត្រី ................................................................................................ ១០

៦. សកម្មភាពនានាដើម្បីលើកស្ទួយស្ត្រីចូលរួមក្នុងវិស័យនយោបាយ ...................................... ១១

**III.** ករណីសិក្សានៅខេត្តកណ្តាល តាកែវ និងកំពង់ធំ ................................................................... ១២

**IV.** សេចក្តីសន្និដ្ឋាន/អនុសាសន៍ ..........................................................................................២០

# អារម្ភកថា

របាយការណ៍ **"ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងការបោះឆ្នោត"** គឺជាកំរងនៃការវិភាគទៅលើទិន្នន័យ និងមតិរបស់ស្ត្រីកម្ពុជាចូលរួមក្នុងកិច្ចការនយោបាយ ជាពិសេសក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអណតិទី៤ ឆ្នាំ២០០៨កន្លងទៅនេះ។

របាយការណ៍នេះ បង្ហាញ ការវាយតំលៃនៃការចូលរួមរបស់ស្រីក្នុងនយោបាយ និងការបោះឆ្នោត អំពីចំនួនបេក្ខជនស្ត្រី និងស្ត្រីជាប់ឆ្នោត គោលនយោបាយរបស់គណបក្ស អំពីបញ្ហាស្ត្រី មតិស្ត្រីនៅក្នុងកិច្ចការបោះឆ្នោត និងសកម្មភាពនានាដែលទាក់ទងទៅនឹងការលើកស្ទួយស្ត្រីចូលរួមក្នុងវិស័យនយោបាយជាដើម។ ដោយឡែករបាយកាណ៍នេះ ក៏ផ្តល់ការរកឃើញ ពីការស្រាវជ្រាវនៅក្នុងខេត្តបីគឺ ខេត្តតាកែវ កំពង់ធំ និងកណ្តាលដែលទាក់ទងទៅនឹងមតិនៃការចូលរួមរបស់ស្ត្រីក្នុងការបោះឆ្នោត ហើយជាចុងក្រោយរបាយការណ៍មានអនុសាសន៍ផងដែរ។

**ខុមហ្វ្រែល** សង្ឃឹម ថាបាយការណ៍នេះ ជាឯកសារដ៏សំខាន់ សំរាប់អ្នកអនុវត្តសកម្មភាព និងអ្នកស្រាវជ្រាវដើម្បីជួយលើកស្ទួយស្ត្រីចូលរួមក្នុងនយោបាយ និងក្នុងការធ្វើសេចក្តីសំរេច ។

ខ្ញុំសំដែងនូវការកោតសរសើដល់ក្រុមការងារស្រាវជ្រាវរួមមាន អ្នកស្រី **សឺនកេត សិរីលក្ខណ៍** កញ្ញា **មឿន សុខមុន្នី** លោក **សូ មេន** លោក **តែម ផារ័ត្ន** លោក **នៅ សម្បត្តិ** និងអ្នកសង្កេតការណ៍ ដែលបានខិតខំរៀបចំផែនការចាត់ចែងសកម្មភាព ហើយប្រមូលទិន្នន័យដើម្បីផលិតបានរបាយការណ៍នេះ។ ខ្ញុំក៏សូមថ្លែងអំណរអរគុណដល់អ្នកផ្តល់យោបល់ និងអ្នកបកប្រែ គឺអ្នកស្រី **លី ខេង** និងអ្នកស្រី **រូ គ្រីហ្វីស** (**ROO Griffiths**) ដែលបានចំណាយពេលវេលាដ៏មានដំលៃរបស់ខ្លួន និង ចូលរួមកែលំអររបាយការណ៍នេះ។

ជាពិសេសតាងនាមឱ្យ **ខុមហ្វ្រែល** ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះម្ចាស់ជំនួយជាច្រើនដូចជា **Oxfam Novib, Forum Syd, Trocaire, NPA,** ដែលបាន និងកំពង់បន្តជួយគាំទ្រ និង ឧបត្ថម្ភផ្នែកហិរញ្ញវត្ថុសំរាប់ដំណើរការប្រមូលទិន្នន័យវិភាគ ព្រមទាំងការចងក្រង ការបោះពុម្ពរបាយការណ៍នេះ។

ភ្នំពេញ,ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៩

**គល់ បញ្ញា**

## I- សេចក្តីផ្តើម

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាធានាចំពោះសេរីភាពបុគ្គលជាមូលដ្ឋានមួយចំនួន។ ខណៈដែលប្រទេសកម្ពុជាមានស្ថិរភាពនយោបាយដែលបានជួយសំរួលដល់ការស្តាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងកំណើនសេដ្ឋកិច្ច របាយការណ៍ជាច្រើនអះអាងថា ការធានារបស់រដ្ឋធម្មនុញ្ញត្រូវបានប្រឈមដោយការអនុវត្តច្បាប់នៅខ្សោយ និន្នាការឆ្ពោះទៅរកអតុល្យភាពដែលកើនឡើងរវាងអំណាចប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ ព្រមទាំងកង្វះនូវការញែកឱ្យដាច់ពីគ្នានូវអំណាចទាំងបីនេះ។

ក្រៅពីអតុល្យភាពនៃអំណាចនយោបាយ និងអំណាចរដ្ឋ កម្ពុជាមានបញ្ហាអតុល្យភាពនៃការផ្តល់អំណាចរវាងបុរស និងស្ត្រី។ អ្នកនយោបាយកម្ពុជាភាគច្រើនគឺបុរស។ ឯស្ត្រីវិញមានឱកាសតិចតួចក្នុងការចូលរួមក្នុងឆាកនយោបាយ។ ផ្នែកខ្លះនៃបញ្ហានេះកើតឡើងដោយសារទំនៀមទំលាប់អភិរក្សនិយម និងវប្បធម៌ ដែលត្រូវបានគេសន្មត់ និងផ្តល់តំលៃស្ត្រីទាបជាងបុរសនៅគ្រប់វិស័យផ្សេងៗនៅក្នុងសង្គម។ ជាងនេះទៅទៀត ភាពក្រីក្រ អវិជ្ជា ការរើសអើង ខ្វះការលើកទឹកចិត្ត និងឱកាស និងអវត្តមាននូវគោលនយោបាយជាក់លាក់ក្នុងការលើកកំពស់ និងផ្តល់ឱកាសដល់ស្ត្រី គឺជាបច្ច័យដែលក្លាយជាឧបសគ្គសំរាប់ស្ត្រីក្នុងការទទួលបាននូវសមភាព និងផលចំណេញពីការចូលរួមក្នុងជីវភាពនយោបាយ និងកិច្ចការសង្គម។

កម្ពុជាមិនទាន់មានសមភាពយេនឌ័រនៃការផ្តល់អំណាចខាងនយោបាយ ពិសេសភាពជាតំណាងអ្នកបោះឆ្នោត ថ្វីបើអ្នកចុះឈ្មោះបោះឆ្នោតជាស្ត្រីមាន៥៣%ក៏ដោយ គឺស្ត្រីជាប់ឆ្នោតជាតំណាងរាស្ត្រមានចំនួនតែ ២២% សំរាប់អាណត្តិទី៤ និងស្ត្រីជាសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់មានចំនួន ២០% នៅអាណត្តិទី២។ យោងតាមរបាយការណ៍ UNDP’s Human Development Index ឆ្នាំ២០០៧/០៨ កម្ពុជាមានកំរិតទាបនៃសមធម៌យេនឌ័រនៅក្នុងអាស៊ី សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័រ (០,៥៩៤) និងកំរិតសន្ទស្សន៍ការផ្តល់អំណាចយេនឌ័រមាន (០,៣៧៧)។ ទោះបីបានទទួលលទ្ធផលរីកចំរើនខ្លះនៅក្នុងគោលនយោបាយលើកស្ទួយសមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រគឺនៅតែប្រឈមច្រើន ហើយនយោបាយកំណែទំរង់ និងការអនុវត្តគោលនយោបាយ នៅមានភាពទន់ខ្សោយនៅឡើយ។

បើទោះបីរាជរដ្ឋាភិបាលកម្ពុជាមានភាពជឿនលឿនមួយទៀតដែលពីមុនពុំធ្លាប់មាន គឺការតែងតាំងអភិបាលរងរាជធានី ខេត្តជាស្ត្រីចំនួន ២៣រូប គ្រប់រាជធានី ខេត្តលើកលែងតែខេត្តកែប[១] និងអភិបាលរងស្រុក/ខណ្ឌ ចំនួន ១៦៩រូបក្នុងចំណោម ១៨៥ស្រុក/ខណ្ឌក៏ដោយ នៅមានកង្វះខាតការប្តេជ្ញាចិត្តពីតំណាងអ្នកបោះ-

---

(១) អនុក្រឹត្យ ស្តីពី " ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី១ " ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩

ឆ្នោតនៅថ្នាក់ជាតិ និងរាជរដ្ឋាភិបាលក្នុងការបង្កើតឱ្យមានក្របខណ្ឌច្បាប់គ្រប់គ្រាន់ ដើម្បីលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ។ ផ្ទុយមកវិញ ទាំងមន្ត្រីជាប់ឆ្នោត និងតំណាងរាស្ត្រមាននិន្នាការជំរុញទៅមុខនៃការអនុវត្តរបស់រាជរដ្ឋាភិបាលតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ស្របទៅតាមខ្សែបន្ទាត់គណបក្សនយោបាយរបស់ខ្លួន។

កម្ពុជាបានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើកទី៤របស់ខ្លួននាថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៨ ដែលការបោះឆ្នោតលើកទី១បានរៀបចំដោយអ៊ុន តាក់ នៅឆ្នាំ ១៩៩៣។ ចាប់តាំងពីឆ្នាំ១៩៩៣មក ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវបានរៀបចំរៀងរាល់ប្រាំឆ្នាំម្តងតាមរដ្ឋធម្មនុញ្ញដោយកម្ពុជាខ្លួនឯង។ ហើយក៏មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នាឆ្នាំ២០០២ និងឆ្នាំ២០០៧។

ការបោះឆ្នោតនៅកម្ពុជា មិនទាន់មានលក្ខណៈតាមស្តង់ដារអន្តរជាតិ ។ នៅក្នុងដំណាក់កាលនៃការបោះឆ្នោតបញ្ហានៃភាពមិនប្រក្រតី ឃាដកម្មនយោបាយ ការគំរាមកំហែង បញ្ហាកំហុសបច្ចេកទេស និងបញ្ហាផ្សេងៗទៀតបានកើតឡើងឥតឈប់ឈរ ទោះបីជាច្បាប់បោះឆ្នោត និងបទបញ្ជា នីតិវិធី គ.ជ.ប បានចែងពីការដាក់ទោសទណ្ឌចំពោះអ្នកប្រព្រឹត្តល្មើស ក្រុមមនុស្ស ឬ គណបក្សនយោបាយដែលបានប្រព្រឹត្តិខុសច្បាប់យ៉ាងណាក៏ដោយ ប៉ុន្តែបញ្ហានៃការជម្រុញការអនុវត្តច្បាប់ បទបញ្ជា និងនីតិវិធីទាំងនោះនៅមានកំរិតទាប និងមានភាពលំអៀងនៅឡើយ។

ទោះបីយ៉ាងណាក៏ដោយគេបានកត់សំគាល់ថា ការបោះឆ្នោតឆ្នាំ២០០៨នេះ បានផ្តល់ឱកាសយ៉ាងសំខាន់ដើម្បីបង្កើតការជឿជាក់ពីសាធារណៈនៅក្នុងដំណើរការបោះឆ្នោត និងថយចុះអំពើហិង្សា។

សំរាប់ការបោះឆ្នោតឆ្នាំ២០០៨នេះ មានកៅអីក្នុងសភាចំនួន១២៣ ដែលត្រូវប្រកួតប្រជែងដោយបេក្ខជនចំនួន២៤៧៨នាក់ (ពេញសិទ្ធិ ១១៦២នាក់ និងបម្រុង ១៣១៦នាក់) ក្នុងនោះបេក្ខជនស្ត្រីមានចំនួន ៤២២នាក់ (ពេញសិទ្ធិ ១៧២នាក់ ស្មើនឹង ១៤,៨០% និងបម្រុង ២៥០នាក់ ស្មើនឹង១៩%) មកពីគណបក្សនយោបាយចំនួន១១ និងមានតែ៨គណបក្សនយោបាយប៉ុណ្ណោះ ដែលបានរៀបចំបញ្ជីបេក្ខជនឈរឈ្មោះនៅមណ្ឌលនៃរាជធានី ខេត្តទាំង ២៤។

លទ្ធផលបោះឆ្នោតបង្ហាញឱ្យឃើញថា មានគណបក្សចំនួន **៥**បានទទួលសម្លេងឆ្នោតគាំទ្រពីប្រជាពលរដ្ឋ និងមានអាសនៈនៅក្នុងរដ្ឋសភា មានដូចជា គណបក្សប្រជាជនកម្ពុជា ចំនួន ៩០អាសនៈ គណបក្សសម រង្ស៊ី ចំនួន ២៦អាសនៈ គណបក្សសិទ្ធិមនុស្ស ចំនួន ៣អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច ចំនួន ២អាសនៈ និងគណបក្សនរោត្តម រណឫទ្ធិ ចំនួន ២អាសនៈ។ ក្នុងចំនួនសរុប ១២៣អាសនៈ បេក្ខជនស្ត្រីជាប់ឆ្នោតក្លាយជាសមាជិកសភាមានចំនួនតែ **២៧រូប** ស្មើនឹង **២២%** (មកពីគណបក្សប្រជាជនកម្ពុជា និង គណបក្សសម រង្ស៊ី) ប៉ុណ្ណោះ។

ខាងក្រោមនេះ គឺជាការសិក្សាបន្ថែមនៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងស្រាវជ្រាវទៅលើមតិរបស់ស្ត្រីក្នុងការចូលរួមបោះឆ្នោតឆ្នាំ២០០៨ កន្លងមក។

## II- ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨

### ១- បេក្ខជនស្ត្រី និងតំណាងស្ត្រីជាប់ឆ្នោត

### ១.១. ការជ្រើសរើសបេក្ខជនស្ត្រី

គណបក្សនយោបាយសំខាន់ៗដែលមានអាសនៈនៅក្នុងសភា និងក្រុមប្រឹក្សាឃុំ សង្កាត់បានលើកឡើងនូវបញ្ហាស្រដៀងគ្នាទាក់ទងនឹងការតែងតាំងបេក្ខជន។ មានការពន្យល់តួញត្អែរពីអ្នកដឹកនាំគណបក្សខ្លះថា នៅពេលពួកគេបានដាក់បេក្ខជនស្ត្រី គណបក្សរបស់ពួកគេមានការធ្លាក់ចុះសន្លឹកឆ្នោតគាំទ្រ ឬក៏ពុំបានទទួលសន្លឹកឆ្នោត និងអាសនៈក្នុងសភា។ ការដាក់ស្ត្រីនៅក្នុងបញ្ជីបេក្ខជន គឺជា "ការលះបង់"។ ពួកគេបានលើកឡើងបន្ថែមថា ការដាក់បញ្ជីបេក្ខជនឈរឈ្មោះ គឺផ្អែកលើសមត្ថភាព ប្រជាប្រិយភាព ឆន្ទៈមុះមុត និងមានប្រវត្តិនយោបាយយូរ។ ការតួញត្អែរ និងលក្ខណៈវិនិច្ឆ័យដែលបានលើកឡើងទាំងនេះជាឧបសគ្គមួយយ៉ាងធំសំរាប់បេក្ខនារីដែលមានបំណងឈរឈ្មោះដើម្បីឱ្យគេបោះឆ្នោតឱ្យ។ មុនការចុះបញ្ជីបេក្ខជនឈរឈ្មោះ ទាំងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដូចជាគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (គសន/ CPWP) ដែលមានអង្គការជាសមាជិកចំនួន៧ ដូចជា ខុមហ្វ្រែល(COMFRL) និកហ្វិច(NICFEC) ចំរើនស្ត្រី (WfP) យេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា(CDRI) សីលការ (SILAKA) និងសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍(CWPD)បានជំរុញបង្កើនយុទ្ធនាការ និងបញ្ចុះបញ្ចូលគណបក្សនយោបាយក្នុងការរៀបចំបញ្ជីបេក្ខជនឈរឈ្មោះឆ្លាស់គ្នារវាងបុរស និងស្ត្រី ឬ នៅលេខរៀងខាងលើ ធ្វើយ៉ាងណាផ្តល់ឱកាសឱ្យស្ត្រីមានលទ្ធភាពជាប់ឆ្នោត។ ជាក់ស្តែង សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើកនេះ ក្នុងចំណោមគណបក្សនយោបាយចំនួន៣ (គណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិច)តួលេខបានបង្ហាញថា បេក្ខជនស្ត្រីឈរឈ្មោះជាមធ្យមនៅលេខរៀងទី១ ដល់ ទី៣ គឺ គណបក្សប្រជាជនកម្ពុជា មានការកើនឡើងច្រើនពី ៣,៦១% ទៅ ១០,២៧% និងគណបក្សសម រង្ស៊ី មានការ កើនឡើងបន្តិចបន្តួចពី ១២,២២% ទៅ ១៣,០៦%។ មានបេក្ខជនស្ត្រី និងគណបក្សនយោបាយជាច្រើនបានឱ្យ អ្នកសង្កេតការណ៍ដឹងថា ការរើសអើងប្រឆាំងនឹងបេក្ខជនស្ត្រីដែលពួកគេជួបប្រទះ គឺក្នុងពេលដំណើរការតែងតាំង បេក្ខជន និងការបោះឆ្នោតជ្រើសរើសបេក្ខជននៅក្នុងគណបក្ស។ អ្នកនយោបាយបុរសភាគច្រើនបានលើកឡើងថា ពួកគេមានការលំបាកក្នុងការជំរុញ និងលើកទឹកចិត្តបេក្ខជនស្ត្រីឱ្យចូលរួមក្នុងវិស័យនយោបាយឱ្យបានច្រើន តើមានការលំបាកមែនទេ? ឬក៏ជាលេស?។ កត្តាផ្សេងទៀតត្រូវបានរកឃើញថា ការជ្រើសបេក្ខជនស្ត្រីនៅជួរលើនៃបញ្ជីបេក្ខជនឈរឈ្មោះ គឺជាការប្រឆាំងទៅនឹងបេក្ខភាពបុរស។ ជាង

នេះទៅទៀត បរិយាកាសនយោបាយក្នុងអំឡុងពេល នៃដំណើរការបោះឆ្នោតម្តងៗ គេសង្កេតឃើញមានការគំរាមកំហែង និងបញ្ហាជាច្រើនទៀតដែលធ្វើឱ្យមានឥទ្ធិពលជាអវិជ្ជមានដល់ស្ត្រី និងធ្វើឱ្យពួកគេរារែកក្នុងការចូលរួមក្នុងនយោបាយ។ ប្រការសំខាន់មួយទៀតដែលគួរកត់សំគាល់ គឺគេមិនឃើញមានអ្នកនយោបាយ ស្ត្រីណាម្នាក់មានវត្តមាននៅពេលមានការប្រជុំ រវាងអ្នកសង្កេតការណ៍របស់សហគមន៍ អឺរ៉ុប អ្នកដឹកនាំគណបក្សនយោបាយ និងមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលថ្នាក់ជាតិចំពោះការបោះឆ្នោតលើកនេះ ដែលមានបេក្ខជនស្ត្រីចំនួន១៧២នាក់ ស្មើនឹង ១៤.៨០%នៃចំនួនសរុប ១១៦២នាក់ ចូលរួមនោះទេ។

សូមបញ្ជាក់ផងដែរថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ឆ្នាំ២០០៣ មានបេក្ខជនស្ត្រីឈរឈ្មោះចំនួន ២៧% មកពីគណបក្សចំនួន ២៣។ តួលេខនេះបង្ហាញឱ្យឃើញថា ការបោះឆ្នោតអាណត្តិទី៤ ចំនួនបេក្ខជនស្ត្រីឈរឈ្មោះមានការថយចុះ ១២,២០%។ ទោះជាយ៉ាងនេះក៏ដោយ គណបក្សប្រជាជនកម្ពុជា មានបេក្ខជនស្ត្រីកើនឡើងពី ១៤នាក់ ស្មើនឹង ១១,៣៨% (២០០៣) ទៅ ២០នាក់ ស្មើនឹង ១៦,២៦% (២០០៨) និងគណបក្សសម រង្ស៊ី មានបេក្ខជនស្ត្រីកើនឡើងពី ១៥នាក់ ស្មើនឹង ១២,១៩% (២០០៣) ទៅ ១៧នាក់ ស្មើនឹង ១៣.៨២% (២០០៨)។

**តារាងទី១: ចំនួនបេក្ខជនស្ត្រីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ទាំង១១គណបក្ស**

| ល.រ | ឈ្មោះគណបក្ស | ស្ត្រីពេញសិទ្ធិ | ភាគរយ | ស្ត្រីបម្រុង | ភាគរយ | ចំនួនមណ្ឌល |
|---|---|---|---|---|---|---|
| ១ | ប្រជាជនកម្ពុជា | ២០ | ១៦.២៦% | ២៦ | ១៨.៣០% | ២៤ |
| ២ | ហង្សដារ៉ាចលនាប្រជាធិបតេយ្យ | ១០ | ៨.១៣% | ១៧ | ១២.០៥% | ២៤ |
| ៣ | នរោត្តម រណឫទ្ធិ | ១១ | ៨.៩៤% | ១៥ | ១០.៦៤% | ២៤ |
| ៤ | ហ៊្វុនស៊ិនប៉ិច | ១០ | ៨.១៣% | ១៦ | ១១.៣៤% | ២៤ |
| ៥ | សិទ្ធិមនុស្ស | ៦ | ៤.៨៧% | ៣ | ២.១២% | ២៤ |
| ៦ | សង្គមយុត្តិធម៌ | ១៤ | ៣០.៤៣% | ១៨ | ៣៩.១៣% | ៧ |
| ៧ | សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ២៤ | ១៩.៥១% | ៤៣ | ៣០.៤៩% | ២៤ |
| ៨ | សម រង្ស៊ី | ១៧ | ១៣.៨២% | ១៦ | ១១.៣៤% | ២៤ |
| ៩ | ខ្មែរឈប់ក្រ | ១៤ | ២៣.៣៣% | ២៩ | ៤៨.៣៣% | ៧ |
| ១០ | ប្រជាធិបតេយ្យខ្មែរ | ៣៧ | ៣០% | ៥៣ | ៣៥.៨១% | ២៤ |
| ១១ | ខ្មែរសាធារណរដ្ឋ | ៩ | ១២.៥០% | ១៤ | ១៩.៤៤% | ៩ |
| | **ចំនួនសរុប ១១ គណបក្ស** | **១៧២** | **១៤.៨០%** | **២៥០** | **១៩%** | |

## ១.២. តំណាងស្ត្រីជាប់ឆ្នោត

ទោះបីជាចំនួនស្ត្រីជាប់ឆ្នោតនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិនេះ មានការកើនឡើងបន្តិចបន្តួចបើធៀបនឹងការបោះឆ្នោតមុនៗ (១៨នាក់ ស្មើនឹង១៤,៦៣%ក្នុងឆ្នាំ២០០៨ និង១៩នាក់ ស្មើនឹង១២,១៩% ក្នុងឆ្នាំ២០០៣ ជាប់ឆ្នោតភ្លាមៗ)។ អង្គការសង្គមស៊ីវិល (ឬ ខុមហ្វ្រែល)សូមសម្តែងការអបអរសាទរចំពោះការរៀបចំរដ្ឋាភិបាលថ្មី ដែលបានផ្លាស់ប្តូរបេក្ខជនឈរឈ្មោះជាស្ត្រីលេខរៀងបន្ទាប់មួយចំនួនជំនួសអ្នកតំណាងរាស្ត្រជាបុរសដែលទៅកាន់កិច្ចការរដ្ឋាភិបាល ដូចនេះហើយបន្ទាប់

អាណត្តិទី៥ នៅឆ្នាំ២០១៣ មានការកើនចំនួនស្ត្រីជាប់ឆ្នោតបន្ថែម **១,៦៨%** ដូចនេះអាណត្តិទី៥បានកើនចំនួនស្ត្រីត្រឹមតែ **២៣,៦៨%** ប៉ុណ្ណោះ (ក្នុងករណីសន្មត់ថា ការអនុវត្តន៍យុទ្ធសាស្ត្រ និងគោលនយោបាយរបស់គណបក្សនយោបាយ និងរាជរដ្ឋាភិបាលដូចគ្នានឹងអាណត្តិទី៤ ឆ្នាំ២០០៨)។

**តារាងទី២: ចំនួនបេក្ខជនស្ត្រីជាប់ឆ្នោតអាណត្តិទី៤**

| **ល.រ** | **ស្ត្រីជាប់ឆ្នោតអាណត្តិទី៤** | | | **អាសនៈទទួលបាន** |
|---|---|---|---|---|
| | **គណបក្ស** | **ជាប់ឆ្នោត** | **ភាគរយ** | |
| ១ | ប្រជាជនកម្ពុជា | ២១រូប | ២៣.៣៣% | ៩០ |
| ២ | សម រង្ស៊ី | ០៦រូប | ២៣.០៧% | ២៦ |
| ៣ | សិទ្ធិមនុស្ស | 0 | | ៣ |
| ៤ | ហ៊្វុនស៊ិនប៉ិច | 0 | | ២ |
| ៥ | នរោត្តម រណឫទ្ធិ | 0 | | ២ |
| **សរុប** | | **២៧រូប** | **២២%** | **១២៣** |

## ២. គោលនយោបាយរបស់គណបក្ស អំពី បញ្ហាស្ត្រី

ក្នុងដំណើរការយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០០៨ ចាប់ពីថ្ងៃទី២៦ ខែមិថុនា ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ គណបក្សនយោបាយទាំង១១ បានធ្វើសកម្មភាពឃោសនាដើម្បីបង្ហាញដល់អ្នកបោះឆ្នោតនូវគោលនយោបាយរបស់ខ្លួនដែលទាក់ទិន បញ្ហាស្ត្រី និងកុមារ ដើម្បីដោះស្រាយក្នុងអាណត្តិទី៤នេះ។

គោលនយោបាយ និងការសន្យាសំខាន់ខាងក្រោមនេះ បានដកស្រង់ចេញពីឯកសាររបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ស្តីពី សេចក្តីណែនាំដល់អ្នកបោះឆ្នោតតាមលិខិតយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ និងដកស្រង់ចេញពីវេទិកាពិភាក្សានយោបាយ ស្តីពី វិធានការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ដែលរៀបចំដោយខុមហ្វ្រែល កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៨ ជាមួយគណបក្សនយោបាយចំនួន១០ ព្រមទាំងបានដកស្រង់ចំណុចខ្លះពីឯកសារគោលនយោបាយលើកស្ទួយសិទ្ធិស្ត្រី និងកុមាររបស់គណបក្សប្រជាជនកម្ពុជា (ដោយសារគណបក្សប្រជាជនកម្ពុជាអវត្តមាននៅក្នុងវេទិកាពិភាក្សា)។

**តារាងទី៣: គោលនយោបាយ យុទ្ធសាស្ត្រ និងអនុសាសន៍របស់គណបក្សដើម្បីដោះស្រាយបញ្ហាស្ត្រី និងកុមារ**

| **ល.រ** | **គោលនយោបាយរបស់គណបក្ស** | **ឈ្មោះគណបក្សនយោបាយ** |
|---|---|---|
| ១ | ប្រឆាំងការរំលោភច្បាប់និទណ្ឌភាព អំពើពុករលួយ អំពើហិង្សា ការជួញដូរ | - គណបក្សប្រជាជនកម្ពុជា |

| | | |
|---|---|---|
| | មនុស្ស ជួញដូរគ្រឿងញៀន ឧក្រិដ្ឋកម្ម និងរើសអើងគ្រប់រូបភាព។ | - គណបក្សសម រង្ស៊ី<br>- គណបក្សសិទ្ធិមនុស្ស<br>- គណបក្សនរោត្តម រណឫទ្ធិ<br>- គណបក្សហ៊្វុនស៊ិនប៉ិច<br>- គណបក្សខ្មែរឈប់ក្រ<br>- គណបក្សប្រជាធិបតេយ្យខ្មែរ<br>- គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ<br>- គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ<br>- គណបក្សខ្មែរសាធារណរដ្ឋ |
| ២ | បង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីនៅគ្រប់កម្រិត/វិស័យឱ្យបានជាអតិបរមាក្នុងស្ថាប័នជាតិ និងអង្គការសង្គមផ្សេងៗ សំដៅពង្រីកលទ្ធភាពឱ្យស្ត្រីបានចូលរួមកាន់តែសកម្មក្នុងការធ្វើសេចក្តីសម្រេចនានា ការកសាងផែនការអភិវឌ្ឍន៍ និងអភិបាលកិច្ចទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងយកចិត្តទុកដាក់អប់រំបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពស្ត្រី និងធ្វើឱ្យស្ត្រីកាន់តែមានការជឿជាក់លើតួនាទីរបស់ខ្លួនក្នុងសង្គម។ | - គណបក្សប្រជាជនកម្ពុជា<br>- គណបក្សសម រង្ស៊ី |
| ៣ | ត្រួតពិនិត្យឱ្យបានត្រឹមត្រូវលើក្រុមហ៊ុនដែលនាំពលការនីទៅក្រៅប្រទេស និងជនបរទេសធ្វើការក្នុងស្រុក | - គណបក្សហ៊្វុនស៊ិនប៉ិច<br>- គណបក្សសម រង្ស៊ី<br>- គណបក្សនរោត្តម រណឫទ្ធិ<br>- គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ<br>- គណបក្សសង្គមយុត្តិធម៌<br>- គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ |
| ៤ | បង្កើតប្រពន្ធ័ផ្តល់ប្រាក់កម្ចីសំរាប់ឱ្យយុវជន យុវនារី ចំនួនយ៉ាងតិច ៥០.០០០នាក់ ក្នុងមួយឆ្នាំយកទៅបន្តការសិក្សានៅមហាវិទ្យាល័យ ដោយសងរំលោះវិញរយៈពេលយូរ ពី១៥-៣០ឆ្នាំ ក្រោយពីបញ្ចប់ការសិក្សា ហើយ | គណបក្សសិទ្ធិមនុស្ស |

| | | |
|---|---|---|
| | មានការងារធ្វើ និងមានប្រាក់ខែសមរម្យ ។ | |
| ៥ | បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមូលដ្ឋានសំរាប់យុវជន-យុវនារី ទៅតាមតម្រូវការទីផ្សារ ។ | - គណបក្សសិទ្ធិមនុស្ស<br>- គណបក្សខ្មែរសាធារណរដ្ឋ<br>- គណបក្សសង្គមយុត្តិធម៌ |
| ៦ | ធានាប្រសិទ្ធភាព និងលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិជនជាតិភាគតិច ហើយជម្រុញឱ្យមានការចូលរួមពីស្ត្រីនៅគ្រប់វិស័យ ។ | - គណបក្សប្រជាជនកម្ពុជា<br>- គណបក្សនរោត្តម រណឫទ្ធិ<br>- គណបក្សហ៊្វុនស៊ិនប៉ិច |
| ៧ | លើកកម្ពស់សុខុមាលភាពរបស់ជនចាស់ជរា កុមារកំព្រា ស្ត្រីរងគ្រោះ ជនអនាថា គ្មានទីពឹង អតីតយុទ្ធជន និងក្រុមគ្រួសារ ។ | - គណបក្សប្រជាធិបតេយ្យខ្មែរ<br>- គណបក្សខ្មែរឈប់ក្រ |
| ៨ | បង្ក្រាបមេបន | គណបក្សសង្គមយុត្តិធម៌ |
| ៩ | ប្រើគ្រប់មធ្យោបាយទប់ស្កាត់ និងបង្ក្រាបបទល្មើសនានាមានជាអាទិ៍ : ការជួញដូរស្ត្រី និងកុមារ ហើយសំដៅទៅដល់អជ្ញាធរដែនដីក្នុងស្រុក ក្រសួងការងារ ឬក៏ស្ថានទូតខ្មែរប្រចាំនៅបរទេស ត្រូវយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋដែលទៅធ្វើការនៅក្រៅប្រទេស ហើយទទួលការរំលោភសិទ្ធិសេរីភាព ពិសេសការឆបោក នាំយកទៅលក់ ដោយអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹង ធ្វើការតាមដាន ត្រួតពិនិត្យឱ្យបានទៀងទាត់ និងម៉ត់ចត់ទៅលើក្រុមហ៊ុនឯកជនចូលមករកស៊ីនៅក្នុងស្រុកខ្មែរ និងនាំពលករ ពលការនីទៅធ្វើការនៅក្រៅប្រទេស ជាក់ស្តែង ប្រទេសម៉ាឡេស៊ី ថៃ ។ល។ និង ។ល។ | - គណបក្សសម រង្ស៊ី<br>- គណបក្សនរោត្តម រណឫទ្ធិ<br>- គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ<br>- គណបក្សសង្គមយុត្តិធម៌<br>- គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ |
| ១០ | បិទព័ត៌មានទាំងឡាយណា ដែលចុះផ្សាយទេសចរណ៍ផ្លូវភេទ ដូចជាតាមទស្សនាវដ្ដី តាមគេហទំព័រ នាំឱ្យមានបញ្ហាជួញដូរផ្លូវភេទ ។ | - គណបក្សនរោត្តម រណឫទ្ធិ<br>- គណបក្សខ្មែរសាធារណរដ្ឋ |
| ១១ | ត្រូវទប់ស្កាត់នូវទេសចរណ៍ទាំងឡាយណាដែលមកកម្ពុជា ដើម្បីរកការសប្បាយលើផ្លូវភេទ ឬក៏មកថតវីដេអូអាសអាភាស ដើម្បីធ្វើចរាចរណ៍លក់ទៅក្រៅប្រទេស | - គណបក្សប្រជាជនកម្ពុជា<br>- គណបក្សសម រង្ស៊ី<br>- គណបក្សនរោត្តម រណឫទ្ធិ<br>- គណបក្សខ្មែរសាធារណរដ្ឋ |

| | | |
|---|---|---|
| ១២ | បង្កើនការផ្សព្វផ្សាយ ការអប់រំវគ្គខ្លី តាមវិទ្យុ និងទូរទស្សន៍ ឬសារព័ត៌មានទស្សនាវដ្តីផ្សេងៗ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងច្បាស់លាស់អំពីបញ្ហាផលប៉ះពាល់ និងល្បិចកលនៃការជួញដូរ រំលោភផ្លូវភេទប្រឆាំងនឹងស្ត្រី និងកុមារ និងត្រូវមានវគ្គបណ្តុះបណ្តាលធនធានមនុស្ស និងចំណេះដឹងទូទៅចាប់ពីភូមិ ឃុំរហូតដល់ខេត្ត ក៏ដូចជាពង្រឹងបណ្តាញនៅក្នុងសហគមន៍ និងបង្កើតឱ្យមានវិជ្ជាជីវៈដល់ស្ត្រី និងកុមារដែលទទួលរងគ្រោះ។ | - គណបក្សប្រជាជនកម្ពុជា<br>- គណបក្សសិទ្ធិមនុស្ស<br>- គណបក្សនរោត្តម រណឫទ្ធិ<br>- គណបក្សខ្មែរសាធារណរដ្ឋ |
| ១៣ | លើកស្ទួយសិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារ ពង្រឹងការងារសុខុមាលភាពកុមារផ្តល់ការគាំពារដល់កុមារងាយរងគ្រោះ ដូចជា កុមារកំព្រា កុមារពិការ កុមារនៃគ្រួសារក្រីក្រនៅតាមសហគមន៍។ បង្កើនការអប់រំ ការស្តារនីតិសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមាររងគ្រោះ ទប់ស្កាត់អំពើគាបសង្កត់ និងការធ្វើអាជីវកម្មតាមគ្រប់រូបភាពចំពោះកុមារ។ បន្តជំរុញចលនាបីល្អរបស់កុមារ " កូនល្អ សិស្សល្អ និងមិត្តល្អ" ដើម្បីឱ្យកុមារក្លាយជាពលរដ្ឋល្អនាពេលអនាគត។ | គណបក្សប្រជាជនកម្ពុជា |

## ៣‿ សមាជិកស្ត្រីរបស់គ.ជ.ប គធ/ខប គឃ/សប និងការិយាល័យបោះឆ្នោត

ស្ត្រីនៅមានចំនួនតិចតួចនៅក្នុងតួនាទីជាអ្នកគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត។ គឺមានស្ត្រីតែ២រូបប៉ុណ្ណោះក្នុងចំណោមសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ៩រូប និងមានស្ត្រីតែ១៥៣នាក់ស្មើនឹង ១៧,៧៩% ដែលជាបុគ្គលិកបំរើការងារនៅទីស្តីការគ.ជ.ប ។ ចំនួនស្ត្រីរឹតតែតិចតួចថែមទៀតចំពោះគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោមៗដូចជា គណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត (គធ/ខប) មានចំនួនតែ ១២២នាក់ ស្មើនឹង ១០% និងគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប)មានចំនួន ១៤៦៤នាក់ ស្មើនឹង ១៣,០២% ប៉ុណ្ណោះ។ ប៉ុន្តែបែរជាមានចំនួនច្រើននៅថ្នាក់ទាបជាងនេះទៅវិញ ដូចជាគណៈកម្មការការិយាល័យបោះឆ្នោត (គកប)មានចំនួនស្ត្រី ២៩ ៥៥១នាក់ ស្មើនឹង ៣២,២៩%។ មានចំនួនស្ត្រីតិចតួចបំផុតដែលកាន់តួនាទីក្នុងថ្នាក់សំរេចចិត្តលើការគ្រប់គ្រងការបោះឆ្នោត។ មានតែ១៧%ប៉ុណ្ណោះនៃការិយាល័យបោះឆ្នោតដែលមានស្ត្រីជាប្រធាន។

## ៤‿ អ្នកសង្កេតការណ៍ជាស្ត្រី

ក្នុងការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤នេះ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បណ្តាស្ថានទូតនានាប្រចាំនៅកម្ពុជា ក៏ដូចជាគណបក្សនយោបាយ បានដាក់ពង្រាយអ្នកសង្កេតការណ៍ និង

តំណាងរបស់ខ្លួនតាមឃុំ សង្កាត់ និងតាមការិយាល័យបោះឆ្នោតនៃបណ្តារាជធានី ខេត្ត ក្រុងនីមួយៗ ដើម្បីចូលរួមសង្កេតមើលដំណើរការរៀបចំការបោះឆ្នោត ។ តាមតួលេខផ្លូវការរបស់គ.ជ.ប អ្នកសង្កេតការណ៍ស្ត្រីដែលមកពីអង្គការឯករាជ្យ គឺ មានចំនួនស្ត្រីប្រមាណ ៣៥% ច្រើនជាងភ្នាក់ងារសង្កេតការណ៍ស្ត្រីមកពីគណបក្សនយោបាយមានតែជាង ១៧% ។

-អ្នកសង្កេតការណ៍ជាតិដែលគ.ជ.ប បានអនុញ្ញាតចំនួន ៣១ ២៦២នាក់ ក្នុងនោះស្ត្រីចំនួន ១០ ៩០១នាក់ ស្មើនឹង ៣៤,៨៦%មកពីសមាគម អង្គការមិនមែនរដ្ឋាភិបាលចំនួន៧២។ វត្តមានជាក់ស្តែងនៃអ្នកសង្កេតការណ៍ជាតិក្នុងថ្ងៃបោះឆ្នោតមានតែចំនួន ១៧ ២១៩នាក់ ក្នុងនោះស្ត្រីចំនួន ៦ ០៨២នាក់ ស្មើនឹង ៣៥,៣២% ។

-អ្នកសង្កេតការណ៍អន្តរជាតិសរុបចំនួន ៥៩២នាក់ ក្នុងនោះស្ត្រីចំនួន ១៩៤នាក់ ស្មើនឹង ៣២,៧៧% ដែលមកពីអង្គការអន្តរជាតិ និងបណ្តាប្រទេសនានាចំនួន ២៩។

-តំណាងគណបក្សនយោបាយសរុបចំនួន ១៤០ ៨០៤នាក់ ដែលក្នុងនោះ ស្ត្រីចំនួន ២៤ ៨៦៥នាក់ ស្មើនឹង ១៧,៦៥%ដែលមកពីគណបក្សចំនួន៦នៅដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និង ៩គណបក្សនៅដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

## ៥_ អ្នកបោះឆ្នោតស្ត្រី

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤នេះ ចំនួនប្រជាពលរដ្ឋដែលបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការសរុប **៨ ១២៥ ៥២៩ នាក់** ក្នុងនោះស្ត្រីមានចំនួន **៤ ៣៤៧ ៤០៥នាក់** ស្មើនឹង **៥៣,៥១%**[២] ។ ជាមួយនឹងចំនួនអ្នកបោះឆ្នោតដ៏ច្រើននេះ មានអ្នកបោះឆ្នោតចំនួនតែ **៦ ១១០ ៨២៨នាក់** ស្មើនឹង **៧៥,២១% ប៉ុណ្ណោះ** ក្នុងនោះតាមការប៉ាន់ស្មានអ្នកបោះឆ្នោតស្ត្រីច្រើនជាងបុរសបានទៅបោះឆ្នោតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨។

អ្នកមានសិទ្ធិបោះឆ្នោតចំនួន **២ ០១៤ ៧០១ នាក់មិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោត** ។ ការខកខានមិនបានទៅបោះឆ្នោត និង/ឬមិនបានបោះឆ្នោតនេះ ក៏អាចមានស្ត្រីមួយចំនួនធំផងដែរ។ ពួកគេពិតជាជួបការលំបាកក្នុងការទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត ដោយសារមានភាពមិនប្រក្រតីច្រើនដែលប៉ះពាល់ដល់សិទ្ធិអ្នកបោះឆ្នោតជាងការបោះឆ្នោតមុនៗដូចជា: (១) អ្នកបោះឆ្នោតមិនអាចរកឈ្មោះពួកគេឃើញនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត (២) អ្នកបោះឆ្នោតមិនដឹងអំពីទីតាំងស្ថានីយ៍បោះឆ្នោតដោយពួកគេមិនបានទទួលបណ្ណ័ព័ត៌មាន ឬក៏មិនបានដឹងអំពីការផ្លាស់ប្តូរលេខកូដការិយាល័យបោះឆ្នោត និង (៣) អ្នកបោះឆ្នោតយល់ច្រឡំអំពីការប្រើប្រាស់បណ្ណ័

---

(២) របាយការណ៍របស់គ.ជ.ប ស្តីពី ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះអ្នកបោះឆ្នោត ប្រចាំឆ្នាំ២០០៧ ចេញផ្សាយតាមគេហទំព័រ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨

ព័ត៌មានរបស់ពួកគេសំរាប់ការបោះឆ្នោត។ ជាមួយគ្នានេះដែរ មន្ត្រីជំនួយការការិយាល័យបោះឆ្នោតមិនបានបំពេញតាមភារកិច្ចរបស់ខ្លួនឱ្យពេញលេញ ឬ មិនមានសមត្ថភាពជួយអ្នកបោះឆ្នោតដោះស្រាយបញ្ហាដូចលើកឡើងខាងលើ។

## ៦. សកម្មភាពនានាដើម្បីលើកស្ទួយស្ត្រីចូលរួមក្នុងវិស័យនយោបាយ

ដើម្បីជំរុញ និងលើកស្ទួយស្ត្រីចូលរួមឱ្យកាន់តែច្រើនក្នុងនយោបាយ និងក្លាយជាថ្នាក់ដឹកនាំ សម្រេចចិត្តសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអណត្តិទី៤នេះ មានអង្គការសង្គមស៊ីវិលមួយចំនួនបានដាក់ចេញនូវផែនការ និងធ្វើសកម្មភាពយ៉ាងសស្រាក់សស្រាំ។ តួយ៉ាង គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ(គសន) ដែលមានអង្គការ សមាគមជាក្រុមការងាររួមគ្នាចំនួន ៧ ដូចជា (CDRI, COMFREL, CWPD, GAD/C, NICFEC, SILAKA and WfP) បានដាក់ចេញនូវសកម្មភាពរបស់ខ្លួនជាច្រើន និងធ្វើការយ៉ាងសកម្ម ដើម្បីជួយដល់ស្ត្រីដែលមានបំណងចូលរួមក្នុងឆាកនយោបាយ និងឈរឈ្មោះជាបេក្ខជន សំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ២០០៨ ។ សកម្មភាពទាំងនោះរួមមាន ការបណ្តុះបណ្តាលដល់សកម្មជនគណបក្សនយោបាយ វេទិកាស្ត្រី ការបោះពុម្ព និងផ្សព្វផ្សាយឯកសារអប់រំដល់អ្នកបោះឆ្នោត ការចាក់ផ្សាយរឿងខ្លីអប់រំ ការផ្សព្វផ្សាយកម្មវិធីស្ត្រីតាមវិទ្យុ ទូរទស្សន៍ និងយុទ្ធនាការតស៊ូមតិ និងបញ្ចុះបញ្ចូល ។ល។ និង។ល។ ជាក់ស្តែង ខុមហ្វ្រែលបានធ្វើសកម្មភាពបន្ថែមទៀតយ៉ាងសកម្ម ដូចជា បោះពុម្ព និងផ្សព្វផ្សាយ ទូទាំងប្រទេសនូវសៀវភៅផ្ទត់ចំនួន ៣០០ ០០០សន្លឹក សៀវភៅសំណួរ-ចំលើយចំនួន ៣០ ០០០ក្បាល សៀវភៅរូបភាពចំនួន ៣៣ ១២៥ក្បាល ប្រតិទិនចំនួន ២០ ០០០សន្លឹក ស្ទីគយ័ចំនួន ៩ ០០០សន្លឹក ផលិត និងចាក់ផ្សាយស្ប៉តអប់រំដែលមានរយៈពេល ១១ នាទីតាមរយៈស្ថានីយ៍ទូរទស្សន៍ខ្មែរប៉ុស្តិ៍លេខ៩ និងទូរទស្សន៍ អប្សរាប៉ុស្តិ៍លេខ១១ ចំនួន ៣៨ដង និងចាក់ផ្សាយតាមរយៈការផ្សាយសំលេងសង្គមស៊ីវិលមានវិទ្យុ FM ១០៥ FM ៩០ FM៨៨.៥ និង FM ៩០.២៥ ចំនួន១០ដង ការផ្សាយជាទៀងទាត់តាមវិទ្យុសំលេងសង្គមស៊ីវិល ដែលមានឈ្មោះថា កម្មវិធី "ស្ត្រីអាចធ្វើបាន" ។ បន្ថែមលើនេះទៀត ខុមហ្វ្រែលបានបើកវគ្គបណ្តុះបណ្តាលចំនួន ៣វគ្គដល់សកម្មជនគណបក្សនយោបាយដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ (គណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សនរោត្តម រណប្ញទ្ធិ) នៅស្រុកកំពង់ចាម និងស្រុកកំពង់សៀម ខេត្តកំពង់ចាម និងបានរៀបចំវេទិកាសាធារណៈចំនួន ៤ នៅក្នុងស្រុកកំពង់សៀម ដើម្បីអប់រំ ផ្សព្វផ្សាយដល់អ្នកបោះឆ្នោត និងបានរៀបចំវេទិកាពិភាក្សានយោបាយ ដោយមានការចូលរួមពីគណបក្សនយោបាយប្រកួតប្រជែងសំរាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ដើម្បីបង្ហាញពីគោលនយោបាយរបស់ខ្លួនទាក់ទិននឹងវិធានការ ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ។ ទោះបីជាយ៉ាងណាក៏ដោយ នៅមានកិច្ចការជាច្រើនដែលត្រូវធ្វើដើម្បីបង្កើនចំនួនស្ត្រី និងពង្រឹងសក្តានុពលរបស់ស្ត្រីក្នុងកិច្ចការនយោបាយ និងកិច្ចការសាធារណៈ។

## III-ករណីសិក្សានៅខេត្តកណ្តាល តាកែវ និងកំពង់ធំ

### ១~ គោលបំណង និងវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ

ខុមហ្វ្រែលបានរៀបចំវគ្គហ្វឹកហ្វឺនចំនួន៣វគ្គ នៅ៣ខេត្ត គឺខេត្តកំពង់ធំ កណ្តាល និងតាកែវ ដល់ក្រុមគោលដើម្បីទទួលខុសត្រូវក្នុងការប្រមូលទិន្នន័យ និងការធ្វើសំភាសន៍ដល់អ្នកបោះឆ្នោតជាស្ត្រី។ ការហ្វឹកហ្វឺននេះយើងជ្រើសរើសយកសិស្ស ឬនិស្សិតជាស្ត្រីចំនួន៦០ នាក់ មកបំប៉នស្តីពីរបៀបជ្រើសរើសក្រុមគោលដៅសំរាប់ធ្វើសំភាសន៍ និងរបៀបធ្វើសំភាសន៍ ឬការប្រមូលទិន្នន័យ (មុនពេល កំពុង និងក្រោយ) ការបញ្ជូនរបាយការណ៏ និងការផ្សព្វផ្សាយឯកសារអប់រំអ្នកបោះឆ្នោត។ អ្នកទំនាក់ទំនងស្រុក/ខណ្ឌខុមហ្វ្រែល ជាអ្នកជ្រើសរើសសិក្ខាកាមជាស្ត្រីចំនួន២០នាក់ក្នុងមួយវគ្គឡើងមករៀននៅថ្នាក់ស្រុករយៈពេលមួយព្រឹក រៀនចប់ពួកគាត់ផ្សព្វផ្សាយឯកសារអប់រំអ្នកបោះឆ្នោត និងធ្វើសំភាសន៍ស្ត្រីដែលបានបោះឆ្នោតមានទឹកខ្មៅប្រឡាក់ម្រាមដៃ និងអ្នកដែលមិនបានបោះឆ្នោត (ទឹកថ្នាំគ្មានប្រឡាក់ម្រាមដៃក្នុងម្នាក់សំភាសន៍៦នាក់)។ លើកទីមួយរៀបចំហ្វឹកហ្វឺនដល់អ្នកបោះឆ្នោតជាស្ត្រី ចំនួន២០រូបនៅស្រុកស្ទឹងសែន ខេត្តកំពង់ធំ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៨។ លើកទី២រៀបចំហ្វឹកហ្វឺនដល់អ្នកបោះឆ្នោតជាស្ត្រីចំនួន២០រូប នៅស្រុកស្អាង ខេត្តកណ្តាល និងលើកទី៣ នៅស្រុកដូនកែវ ខេត្តតាកែវ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨។

**ចំនួនសិក្ខាកាម និងអ្នកត្រូវសំភាសន៍ (ក្រុមគោលដៅស្ត្រី)**

| ល.រ | ឈ្មោះស្រុក ខេត្ត | ចំនួនសិក្ខាកាម និងអ្នកសំភាសន៍ | ក្រុមគោលដៅសំភាសន៍ មានទឹកថ្នាំ | ក្រុមគោលដៅ សំភាសន៍គ្មានទឹកថ្នាំ |
|---|---|---|---|---|
| ១ | ស្រុកស្អាង ខេត្តកណ្តាល | ២០ នាក់ | ២០×៣ =៦០ នាក់ | ២០×២ =៤០ នាក់ |
| ២ | ស្រុកដូនកែវ ខេត្តតាកែវ | ២០ នាក់ | ២០×៣ =៦០ នាក់ | ២០×២ =៤០ នាក់ |
| ៣ | ស្រុក សន្ទុក ខេត្តកំពង់ធំ | ២០ នាក់ | ២០×៣ =៦០ នាក់ | ២០×២ =៤០ នាក់ |
| | | **៦០ នាក់** | **១៨០ នាក់** | **១២០ នាក់** |

សំរាប់ការប្រមូលទិន្នន័យ យើងបានធ្វើសំភាសន៍អ្នកបោះឆ្នោតជាស្ត្រី ចំនួន ៣០០ នាក់។ ទំរង់ ត្រឹមត្រូវ២៩០ ទំរង់បញ្ជីសំណួរ និងខូចអស់១០ទំរង់បញ្ជីសំណួរ បន្ទាប់ពីសំអាតបញ្ជីរួច ទំរង់បញ្ជីសំណួរទាំង២៩០ មានអ្នកដែលមិនបានទៅបោះឆ្នោត (ម្រាមដៃគ្មានប្រឡាក់ទឹកថ្នាំ) ចំនួន៩០ ទំរង់។ រីឯការសំភាសន៍ជាក្រុមយើងបានរៀបចំជា៣

ក្រុម ក្នុងមួយខេត្តយើងយកមួយក្រុម ដែលក្រុមនីមួយៗមានអ្នកទៅបោះឆ្នោត និងមិនទៅបោះឆ្នោត ចាប់ពី៨នាក់ទៅ១១នាក់ ។

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងដើម្បីសិក្សាស្វែងយល់ពីគំនិត ទស្សនៈ និងការយល់ឃើញរបស់ស្ត្រីចូលរួមក្នុងវិស័យនយោបាយ ជាពិសេសទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ និងស្វែងយល់អំពីមូលហេតុ ឧបសគ្គ ការសំរេចចិត្តទៅបោះឆ្នោត ឬ មិនទៅបោះឆ្នោតរបស់ស្ត្រីដែលមាន អាយុចាប់ពី១៨ឆ្នាំឡើងទៅ និងមូលហេតុដែលធ្វើឱ្យចំនួនអ្នកបោះឆ្នោតថយចុះ។ ការសិក្សាស្រាវជ្រាវនេះនឹងពិនិត្យផងដែរពីការចូលរួមឈរឈ្មោះ និងទិសដៅអនាគតរបស់បេក្ខជនស្ត្រីក្នុងការបោះឆ្នោត។

វិធីសាស្ត្រដើម្បីប្រមូលទិន្នន័យនេះ ក្រុមការងារបានបង្កើតសំណួរលំអិតជាប្រភេទគឺ សំណួរបែប បរិមាណ និងសំណួរបែបគុណភាព ក្នុងនោះដែរការសម្ភាសន៍ជាក្រុមត្រូវបានធ្វើដោយឡែកពីគ្នាដែរ ដែលមានដូចជាក្រុមស្ត្រីជាប្រជាពលរដ្ឋសុទ្ធសាធ។ សំណួរទាំងនោះផ្តោតទៅលើដំណើរការបោះឆ្នោតក្នុងអាណត្តិទី៤នេះ ដូចជាៈ

***១-តើអ្នកធ្លាប់បានចូលរួមក្នុងដំណើរការ [សកម្មភាព] យុទ្ធនាការឃោសនាបោះឆ្នោតដែរ ឬទេ ?***

***២-តើអ្នកទៅបោះឆ្នោតដើម្បីអ្វី? មូលហេតុអ្វី?***

***៣-តើអ្នកសង្ឃឹមថានឹងទទួលបានអ្វី ទើបអ្នកសំរេចចិត្តបោះឆ្នោតអោយ?***

***៤-តើមូលហេតុអ្វីបានជាអ្នកមិនបានទៅបោះឆ្នោត ? [អ្នកត្រូវសំភាសន៍គ្មានទឹកថ្នាំខ្មៅនៅជាប់ម្រាមដៃជាអ្នកមិនបានទៅបោះឆ្នោត]***

***៥- តើអ្នកយល់ថា ការចូលរួមរបស់ស្ត្រីមានសារៈសំខាន់ទេសំរាប់ការបោះឆ្នោតលើកនេះ ? [ក្នុងការធានាសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី]***

***៦- តើអ្នកយល់ថា មានសារៈសំខាន់ទេចំពោះការចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតរបស់ស្ត្រី ?***

## ២. ការបកស្រាយទិន្នន័យ

ក្រោយពេលបោះឆ្នោតភ្លាម (នៅថ្ងៃបោះឆ្នោតដដែល ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨) ក្រុមស្រាជ្រាវបានជ្រើសរើសក្រុមគោលដៅជាស្ត្រីសំរាប់ធ្វើសំភាសន៍ទាំងអ្នកបានបោះឆ្នោត និងមិនបានបោះឆ្នោត ចំនួន ៣០០នាក់ ស្មើនឹង៣០០នៃទំរង់បញ្ជីសំណួរ ហើយក្នុងនោះមាន១០ទំរង់បញ្ជីសំណួរមិនបានការ (មិនមានពត៌មានគ្រប់គ្រាន់)។ យោងតាមការធ្វើសំភាសន៍ស្ត្រីដែលបានចូលរួមបោះឆ្នោតក្នុងនោះមាន :

***២.១-តើអ្នកធ្លាប់បានចូលរួមក្នុងដំណើរការ [សកម្មភាព] យុទ្ធនាការឃោសនាបោះឆ្នោតដែរ ឬទេ ?***

| ការសំរេចចិត្តរបស់ស្ត្រីក្នុងការបោះឆ្នោត | ចំនួន | គិតជាភាគរយ |
|---|---|---|

| | | |
|---|---|---|
| មិនបានចូលរួមក្នុងក្បួនឃោសនា | ១២៨ នាក់ | ៥១,២% |
| បានចូលរួមក្នុងក្បួនឃោសនា | ៥៥ នាក់ | ២២,00% |
| ធ្លាប់បានស្តាប់ | ៥៣ នាក់ | ២១,២% |
| មិនចាប់អារម្មណ៍ក្បួនឃោសនា | ១៤ នាក់ | ៥,៦% |
| **សរុប** | **២៥0 នាក់** | **១00%** |

**-៥៧ %** នៃស្ត្រីដែលចូលរួមផ្តល់ចំលើយបានលើកថា ពួកគេមិនបានចូលរួមទាល់តែសោះ។ តាមចំលើយខាងលើឃើញថា ប្រជាពលរដ្ឋជាងពាក់កណ្តាលក្នុងចំណោមអ្នកដែលបានផ្តល់ចំលើយ បង្ហាញភាពមិនអើពើមិនដឹងមិនឮពីការឃោសនាបោះឆ្នោត។ ការមិនចាប់អារម្មណ៍លើការឃោសនាបោះឆ្នោត ដោយសារពួកគេគិតថា ការឃោ-សនាបោះឆ្នោតនឹងមិនមានអ្វីថ្មីសំរាប់ពួកគេ ហើយការឃោសនាបោះឆ្នោតនឹងមិននាំមកការផ្លាស់ប្តូរអ្វីជាដុំកំភួននោះទេ។ ប្រជាពលរដ្ឋមិនទាន់ឃើញពីសារៈសំខាន់នៃកម្មវិធីនយោបាយរបស់គណបក្សដែលបានសន្យាក្នុងពេលបោះឆ្នោតដែលត្រូវបានអនុវត្ត ដើម្បីកែប្រែជីវភាព និងការរស់នៅរបស់ពួកគេបាននោះទេ។

អ្នកខ្លះទៀតគិតថា គួរនៅអព្យាក្រិត្យ អ្នកខ្លះទៀត ឪពុកម្តាយមិនឱ្យទៅចូលរួម ខ្លាចមានបញ្ហាមិនចង់ឱ្យគេដឹងថា ខ្លួនគាំទ្រគណបក្សណាមួយ ខ្លាចមានបញ្ហាចំពោះសន្តិសុខ និងសុវត្ថិភាពផ្ទាល់ខ្លួន។ អ្នកខ្លះទៀតលើកឡើងថា ការឃោសនាមិនសំខាន់ទេ តែការអនុវត្តសំខាន់ជាង ការឃោសនាជារឿងធម្មតា សំខាន់ទៅបោះឆ្នោតរកស៊ីសំខាន់ជាង ព្រោះការបោះឆ្នោតវាជារឿងរបស់អ្នកនយោបាយ គឺធ្វើដើម្បីផ្តល់ប្រយោជន៍ឱ្យគេ (អ្នកនយោ-បាយ)។

**-២២%** លើកឡើងថាធ្លាប់បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពឃោសនា ការចូលរួមក្នុងក្បួនឃោសនានេះ ពួកគាត់មានចំណាប់អារម្មណ៍ផ្សេងៗគ្នា អ្នកខ្លះថាមានភាពអូរអរសប្បាយរីករាយណាស់ ច្រៀងរាំហ៊ោកញ្ជ្រៀវចង់ដឹងពីគោលនយោបាយរបស់គណបក្ស និងពីរបៀបរៀបចំ។ យុវតីខ្លះទៀតថា មេភូមិបានដើរប្រាប់តាមផ្ទះ ខ្លះទៅចូលរួមជំនួសឪពុកម្តាយ។ មានការយល់ដឹងច្រើនពីការឃោសនា បោះឆ្នោតពីគណបក្សនយោបាយ។ ខ្លះថា ទៅចូលរួមតាមគេឯង ចូលរួមសប្បាយមានបាយហូបស្រាប់ ឡានជិះស្រាប់ បានលុយ៥000រៀល។ ខ្លះទៀតថា ទៅចូលរួមជួយគាំទ្រគណបក្សដែលខ្ញុំស្រលាញ់ និងជួយលើកទឹកចិត្ត ស្គាល់មុខបេក្ខជនតំណាងរាស្ត្រផ្ទាល់ អាចប្រៀបធៀបបានថា គណបក្សណាមានលុយ និងអត់លុយ ចង់ផ្សព្វផ្សាយបន្តវាជាមេរៀនមួយស្តីពីការបោះឆ្នោត ដើម្បីគាំទ្រតំណាងរាស្ត្រដែលខ្ញុំស្រលាញ់ ចង់ដឹងពីសកម្មភាពក្នុងកាបោះឆ្នោត។

**-២១ %** ឆ្លើយថាធ្លាប់បានស្តាប់តាមវិទ្យុ និងមើលតាមទូរទស្សន៍ ដោយសារពួកគាត់មានការរវល់នឹងការងាររៀនសូត្រ ការងារផ្សេងៗ និងស្ត្រីមួយចំនួនទៀតរវល់មើលកូន និងចាំផ្ទះ ចង់ដឹងព័ត៌មាន របស់គណបក្ស

នីមួយៗ ស្តាប់នៅផ្ទះរាល់ថ្ងៃ ឃើញថាគ្រប់គណបក្សនិយាយតែផលប្រយោជន៍ និងនិយាយល្អតែរៀងៗខ្លួនមិនដែលឃើញធ្វើអ្វីផង ឱ្យប្រជាពលរដ្ឋយល់ពីតួនាទីខ្លួនក្នុងការសំរេចចិត្ត មានការពេញចិត្ត ណាស់នេះជារបបប្រជាធិបតេយ្យពិតប្រាកដ ដឹងពីថ្ងៃបោះឆ្នោត ការផ្សព្វផ្សាយតាមរយៈសារព័ត៌មាននេះ ល្អណាស់សំរាប់យើងទាំងអស់គ្នាត្រូវតែទៅចូលរួម ។

*ឧទាហរណ៍ "ស្ត្រីនៅភូមិបល្ល័ង្គ ឃុំដីវីជាន់ខ្លា ស្រុកស្ទឹងសែន ខេត្តកំពង់ធំ បានលើកឡើងថាតាមរយៈយុទ្ធនាការឃោសនាបោះឆ្នោត យើងអាចដឹងពីកម្មវិធីនយោបាយរបស់គណបក្ស ការសន្យា ហើយនិងការបង្កើតគោលនយោបាយផ្សេងៗបន្ទាប់ពីគេជាប់ឆ្នោត។ យើងអាចដឹងគណបក្សនយោបាយណា មួយដែលល្អយើងអាចធ្វើការប្រៀបធៀប ហើយនិងធ្វើការសំរេចចិត្តថា ត្រូវដូរ ឬ ត្រូវបោះឆ្នោតជូនអ្នកថ្មី ឬ យ៉ាងណា?"*

### ២.២-តើអ្នកទៅបោះឆ្នោតដើម្បីអ្វី ? មូលហេតុអ្វី ?

ស្ត្រីទៅចូលរួមបោះឆ្នោតភាគច្រើនសំរេចចិត្តដោយខ្លួនឯង យោងតាមការសំភាសន៍ជាក់ស្តែងយើង ឃើញថា:

| ទៅចូលរួមបោះឆ្នោតដើម្បី | ចំនួន | គិតជាភាគរយ |
|---|---|---|
| សំរេចចិត្តបោះឆ្នោតដោយខ្លួនឯង | ១៥១ នាក់ | ៩៦.២% |
| សំរេចចិត្តទៅបោះឆ្នោតតាមគ្រួសារជំរុញ | ៤ នាក់ | ២.៥% |
| ជំរុញពីអាជ្ញាធរ ឬសង្គម | ២ នាក់ | ១.៣% |
| **សរុប** | **១៥៧ នាក់** | **១00%** |

-**៩៦.២%** ស្ត្រីសំរេចចិត្តចូលរួមបោះឆ្នោតដោយខ្លួនឯង ដោយពួកគាត់ចង់បានអ្នកដឹកនាំម្នាក់ដែលមានអត្តចរិតស្លូតត្រង់ មានសីលធម៌ និងគុណធម៌ មានជំហររឹងមាំសំរាប់ជួយដល់ប្រជាជនទន់ខ្សោយ ក្រីក្រ និងជួយដឹកនាំប្រទេសជាតិមានការរីកចំរើនរុងរឿង មានស្ថេរភាពសង្គម និងសន្តិភាព។

-**២.៥%** ស្ត្រីមួយចំនួនតូចបានទៅបោះឆ្នោតតាមគ្រួសារជំរុញ ដោយមូលហេតុទៅបោះឆ្នោតឱ្យតែ រួចខ្លួន។

-**១.៣%** ស្ត្រីទៅបោះឆ្នោតដោយសារការជំរុញពីអាជ្ញាធរ ឬ សង្គម ប៉ុន្តែមានការទើសទាល់មិនចង់ទៅបោះឆ្នោតនាំឱ្យខាតពេលវេលា និងខាតការងារនៅផ្ទះ។

### ២.៣-តើអ្នកសង្ឃឹមថានឹងទទួលបានអ្វី ទើបអ្នកសំរេចចិត្តបោះឆ្នោតអោយ ?

| ការសំរេចចិត្តរបស់ស្ត្រីក្នុងការបោះឆ្នោត | ចំនួន | គិតជាភាគរយ |
|---|---|---|
| មានសារៈសំខាន់ណាស់សំរេចចិត្តបោះឆ្នោតដោយខ្លួនឯង | ១២៣ នាក់ | ៨១.៥% |
| មានសារៈសំខាន់ខ្លះដែរ | ២៣ នាក់ | ១៥.២% |

| | | |
|---|---|---|
| មិនមានសារៈសំខាន់ | ៥ នាក់ | ៣,៣% |
| **សរុប** | **១៥១ នាក់** | **១00%** |

**-៨១,៥%** ស្ត្រីថា សំរេចចិត្តបោះឆ្នោត គឺមានសារៈសំខាន់ណាស់ ដើម្បីជ្រើសរើសតំណាងដែល ខ្លួនពេញចិត្ត គឺសង្ឃឹមថាគាត់អាចជួយដោះស្រាយបញ្ហានានាដែលយើងជួបទុក្ខលំបាក។

-**១៥,២%** យល់ថាមានសារៈសំខាន់ខ្លះដែរ ព្រោះប្រជាជនទាំងអស់គ្នាត្រូវនាំគ្នាទៅបោះឆ្នោត ឱ្យបានគ្រប់ៗគ្នា។

**-៣,៣%** ស្ត្រីថា មិនមានសារៈសំខាន់ទេ ទៅបោះឆ្នោតតាមគេរាល់គ្នា ពួកគាត់យល់ថា " *ទៅបោះក៏បាន មិនទៅបោះក៏បាន* "។

សរុបទៅឃើញថា ប្រជាពលរដ្ឋចង់បានអ្នកដឹកនាំល្អ ប្រជាពលរដ្ឋមានជីវភាពល្អ និងមានការងារធ្វើ។ ម្យ៉ាងទៀតពួកគាត់ចង់បានគណបក្សដែលអាចពង្រឹងតុលាការយុត្តិធម៌ និងដោះស្រាយបញ្ហាអតិផរណា បាន។

*ឧទាហរណ៍: ស្ត្រីមួយចំនួននៅខេត្តតាកែវ ចង់ឃើញប្រទេសយើងមានការរីកចំរើនដូចប្រទេសដទៃ ជាពិសេសកូនចៅរបស់ពួកយើង និងក្មេងៗជំនាន់ក្រោយអាចមានឱកាសបន្តការសិក្សាទៅមហាវិទ្យាល័យ និងមានការងារល្អនៅពេលដែលបញ្ចប់ការសិក្សា។ ប្រសិនបើយើងមានអ្នកដឹកនាំល្អ បញ្ហាអំពើពុករលួយនឹងបានដោះស្រាយ យើងទាំងអស់គ្នានឹងមានការងារធ្វើ មានប្រាក់ខែសមរម្យ ហើយស្ថានភាពរបស់យើងនឹងបានប្រសើរជាមិនខាន។ និយាយដោយស្មោះត្រង់ទៅ ពួកយើងបានព្យាយាមផ្លាស់ប្តូរអ្នកដឹកនាំ តាមរយៈការបោះឆ្នោតលើកនេះដែរ។*

***២.៤-តើមូលហេតុអ្វីបានជាអ្នកមិនបានទៅបោះឆ្នោត ? [អ្នកត្រូវសម្ភាសន៍ គ្មានទឹកថ្នាំខ្មៅនៅជាប់ម្រាមដៃ ជាអ្នកមិនបានបោះឆ្នោត]***

| មូលហេតុមិនបាននៅបោះឆ្នោតបណ្តាលមកពី | ចំនួន | គិតជាភាគរយ |
|---|---|---|
| មិនបានទទួលព័ត៌មាន | ២៥ នាក់ | ៣0,១% |
| បញ្ហាសុខភាព | ១៧ នាក់ | ២0,៥% |
| គ្មានមធ្យោបាយធ្វើដំណើរ | ១៣ នាក់ | ១៥,៧% |
| រវល់ធ្វើការងារ និងរកស៊ី | ៩ នាក់ | ១0,៨% |
| គ្រោះថ្នាក់ចរាចរ | ៧ នាក់ | ៨,៥% |
| មិនចាប់អារម្មណ៍ | ៥ នាក់ | ៦% |
| រវល់ការងារផ្ទះ | ៤ នាក់ | ៤,៨% |
| មិនចេះអក្សរ | ៣ នាក់ | ៣,៦% |

| | | |
|---|---|---|
| **សរុប** | **៨៣ នាក់** | **១០០%** |

**-៣០,១%** ស្ត្រីមិនបានបោះឆ្នោតបានឆ្លើយថា មូលហេតុដែលមិនបានចូលរួមបោះឆ្នោតគឺ មកពីបញ្ហាផ្ទះនៅឆ្ងាយ មិនបានទៅចុះឈ្មោះ គ្មានចុងសន្លឹក គ្មានប័ណ្ណបោះឆ្នោត គ្មានអត្តសញ្ញាណប័ណ្ណ រកឈ្មោះមិនឃើញ (គ្មានឈ្មោះក្នុងបញ្ជី) ច្រឡំម៉ោងបោះឆ្នោត មិនបានទៅពិនិត្យបញ្ជីឈ្មោះ ច្រឡំថាគ្មានប័ណ្ណបោះឆ្នោត គ្មានសិទ្ធិបោះឆ្នោត។

**-២០,៥%** ស្ត្រីខ្លះបានឆ្លើយថា មានបញ្ហាផ្ទាល់ខ្លួន និងសុខភាពមិនអាចទៅបោះឆ្នោតបាន មកពីចាំយូរពេក មានផ្ទៃពោះទៅផ្ទះមុន ឈឺក្បាល អស់កម្លាំង ចាស់ជរា អត់ស្រួលខ្លួន មានជម្ងឺឆ្លងខ្លាចឆ្លងដល់គេឯង ត្រូវទៅមន្ទីរពេទ្យ ឈឺធ្ងន់ចំថ្ងៃបោះឆ្នោត មានជម្ងឺរ៉ាំរ៉ៃ ឆ្លងទន្លេចំថ្ងៃបោះឆ្នោត កូនឈឺដេកពេទ្យ។

**-១៩,៧%** ស្ត្រីខ្លះមិនបានទៅបោះឆ្នោត បណ្តាលមកពីមូលហេតុគ្មានមធ្យោបាយធ្វើដំណើរនៅឆ្ងាយមកដល់ហួសពេលបោះឆ្នោត។

**-១០,៨%** ស្ត្រីខ្លះបានឆ្លើយថា ជាប់រវល់ធ្វើការងារ និងរកស៊ី ព្រោះគាត់មមាញឹកធ្វើចំការ ផ្លាស់ទីលំនៅ ។

**-៨,៤%** បានឆ្លើយថា គ្រោះថ្នាក់ចរាចរមិនបានទៅបោះឆ្នោត។

**-៦%** ចំពោះអ្នកឆ្លើយថា ពុំចាប់អារម្មណ៍ និងខ្ជិលទៅបោះឆ្នោត ជាប់គណបក្សណាដូចតែគ្នា។ ក្នុងនេះមួយចំនួនតូចថា ជាប់រៀនត្រៀមប្រឡងបាក់ឌុប គ្រួសារមិនអើពើនឹងបញ្ហានេះទេ គណបក្សណាជាប់ទំនិញនៅតែថ្លៃដដែលៗ មិនចង់បោះតែម្តង កូនមិនឱ្យទៅបោះ។

- **៤,៨%** ស្ត្រីបានឆ្លើយថា នៅចាំផ្ទះ រីឯអ្នកខ្លះរវល់ការងារផ្ទះ អត់មានអ្នកដាំបាយ

- **៣,៦%** បានឆ្លើយថា មិនចេះអក្សរ មិនទៅបោះឆ្នោត គាត់គ្មានការយល់ដឹងច្បាស់ពីបញ្ហា ឬយុទ្ធសាស្ត្ររបស់មេដឹកនាំគណបក្សនីមួយៗសំរាប់ដឹកនាំប្រទេស ខ្លាចបោះឆ្នោតជ្រើសរើសបានអ្នកដឹកនាំដែលយើងមិនពេញចិត្ត។

***២.៥- តើអ្នកយល់ថា ការចូលរួមរបស់ស្ត្រីមានសារៈសំខាន់ទេសំរាប់ការបោះឆ្នោតលើកនេះ ? [ក្នុងការធានា សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី]***

| **ការចូលរួមរបស់ស្ត្រីមានសារៈសំខាន់** | **ចំនួន** | **គិតជាភាគរយ** |
|---|---|---|
| ឆ្លើយថាមានសារៈសំខាន់ | ២៤១ នាក់ | ៩៦,៤% |
| ឆ្លើយថាមិនមានសារៈសំខាន់ | ៩ នាក់ | ៣,៦% |
| **សរុប** | **២៥០ នាក់** | **១០០%** |

**-ស្ត្រី ៩៦,៤%** ឆ្លើយថាមានសារៈសំខាន់ ព្រោះស្ត្រីមានសិទ្ធិស្មើនឹងបុរសលើគ្រប់បញ្ហាទាំងអស់ មិនមែនមានតែបុរសទេដែលបោះឆ្នោតបាននោះ ទាល់តែមានស្ត្រីចូលរួមទើបមានការរីកចំរើន ស្ត្រីមានការគិតគូល្អិតល្អន់ជាង

បុរស ស្ត្រីងាយស្រួលនិយាយគ្នា បញ្ហាស្ត្រី និងកុមារត្រូវបានដោះស្រាយ កន្លែងខ្លះឃើញស្ត្រីទៅបោះឆ្នោតច្រើនជាងបុរស ស្ត្រីត្រូវបានចាត់ទុកថាជាកំលាំងចលករមួយដ៏សំខាន់នៅក្នុងសង្គម ។ នៅក្នុងគ្រួសារមួយប្រសិនបើគ្មានស្ត្រីចូលរួមទេ គ្រួសារនោះនឹងមានភាពរញ៉េរញ៉ៃជាមិនខាន ។ ម្យ៉ាងទៀត ការងាររបស់ស្ត្រីមានភាពសាំញ៉ាំ និងស្មុគស្មាញច្រើន គឺស្ត្រីដែលជាអ្នកទទួលខុសត្រូវចំពោះភាពសុខដុមរមនារបស់គ្រួសារមិនមែនបុរសទេ ។ ប្រសិនបើយើងនិយាយពីកិច្ចការសង្គម ភាពសុខដុមរមនាក្នុងគ្រួសារ ដូច្នេះ ត្រូវតែមានស្ត្រីចូលរួម ដើម្បីឱ្យមានតុល្យភាពនៅក្នុងសង្គម ។

**-រីឯស្ត្រី ៣,៦%** ឆ្លើយថាមិនសំខាន់ ព្រោះមិនអាចធ្វើការងារសំរេចដូចបុរសបានទេ ស្ត្រីជាមនុស្សទន់ខ្សោយ ការងារផ្ទះច្រើន មើលកូនចៅនៅផ្ទះ ។

### ***២.៦- តើអ្នកយល់ថា មានសារៈសំខាន់ទេចំពោះការចូលរួមឈរឈ្មោះជាបេក្ខជនបោះឆ្នោតរបស់ស្ត្រី ?***

| ការចូលរួមរបស់ស្ត្រីមានសារៈសំខាន់ | ចំនួន | គិតជាភាគរយ |
|---|---|---|
| ឆ្លើយថាមានសារៈសំខាន់ | ២៣៥ នាក់ | ៩៤% |
| ឆ្លើយថាមិនមានសារៈសំខាន់ | ១៥ នាក់ | ៦% |
| **សរុប** | **២៥០ នាក់** | **១00%** |

យោងតាមការធ្វើសំភាសន៍ស្ត្រីដែលបានទៅចូលរួមបោះឆ្នោត និងមិនបានបោះឆ្នោតមាន ÷

**-៩៤%** ស្ត្រីឆ្លើយថា មានសារៈសំខាន់ ព្រោះស្ត្រីមានសិទ្ធិឈរឈ្មោះបោះឆ្នោតដូចបុរសដែរ ដើម្បីជួយលើកស្ទួយស្ត្រីអាចចូលរួមគ្រប់សកម្មភាពក្នុងសង្គម សហគមន៍ និងគ្រួសារ កាលណាមានស្ត្រីឈរឈ្មោះជាបេក្ខជនបោះឆ្នោត ធ្វើឱ្យមានការងាយស្រួលសំរាប់ទាក់ទងគ្នាទៅវិញទៅមក ស្ត្រីអាចយល់ច្បាស់ពីចិត្តស្ត្រីដូចគ្នា ស្ត្រីអាចក្លាយជាអ្នកដឹកនាំ អ្នកអប់រំប្រជាជនបានដែរ ។ ម្យ៉ាងទៀត ស្ត្រីដឹងពីទុក្ខធុរៈស្ត្រីដូចគ្នា បើស្ត្រីជាប់ជាតំណាងរាស្ត្រអាចជួយសំរួលដល់ទុក្ខលំបាក និងការងារស្ត្រី ស្ត្រីជាមាតានៃពិភពលោក ស្ត្រីមានគំនិតចេះអត់ឱន និងអធ្យាស្រ័យ ។ ជួយលើកស្ទួយស្ត្រីឱ្យយល់ដឹងពីសង្គមឱ្យបានច្រើន បើមានស្ត្រីជាអ្នកដឹកនាំ ការរើសអើង ការរំលោភ ការជួញដូរ និងអំពើហឹង្សាលើស្ត្រីត្រូវបានកាត់បន្ថយ ។ ចង់ផ្លាស់ប្តូរអ្នកដឹកនាំ ស្ត្រីមានតំរូវការខុសពីបុរស ស្ត្រីមានឱកាសចូលរួមបញ្ចេញនូវសមត្ថភាពក្នុងការ ដឹកនាំ កសាងអភិវឌ្ឍន៍ប្រទេសជាតិ ។

ស្ត្រីអាចឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យបាន ហើយស្ត្រីអាចនឹងក្លាយជាអ្នកដឹកនាំដ៏ល្អ ព្រោះបើតាមប្រវត្តិសាស្ត្ររបស់យើងកន្លងមកយើងមានស្ត្រីជាអ្នកដឹកនាំល្អៗជាច្រើន ។ ម្យ៉ាងទៀតស្ត្រីក៏មានសិទ្ធិខាង នយោបាយដូចជាបុរសដែរ ។

ស្ត្រីងាយស្រួលនិយាយគ្នា ចិត្តល្អ សំដីទន់ភ្លន់ជាងបុរស ស្ត្រីដឹងបញ្ហាជាច្រើនទាំងបុរស ស្ត្រី កុមារ និងចាស់ជរា យើងជាស្ត្រីត្រូវតែគាំទ្រស្ត្រីដូចគ្នា ។

**-៦%** ស្ត្រីឆ្លើយថាមិនសំខាន់ ព្រោះស្ត្រីជាភេទទន់ខ្សោយ មិនអាចធ្វើការងារដូចបុរសបានទេ។ បងស្រីខ្លះឆ្លើយថាទាំងបុរស ទាំងស្ត្រីសំខាន់ដូចគ្នាឱ្យតែចិត្តល្អចេះដឹងទុក្ខធុរៈរបស់ប្រជាជន ។

ការចូលរួមបោះឆ្នោតរបស់ស្ត្រីមានសារៈសំខាន់ណាស់ ជាពិសេស នៅពេលដែលមានតំណាងជាប់ ឆ្នោតជាស្ត្រី បញ្ហាស្ត្រីនឹងត្រូវបានដោះស្រាយ។ ជាពិសេសនៅពេលដែលស្ត្រីមានបញ្ហា ពួកគេមានការពិបាកក្នុងការរកដៃគូជាបុរសដើម្បីពិភាក្សាយោបល់លើបញ្ហារបស់ពួកគេ ឬការពិភាក្សាបញ្ហាស្ត្រីជាមួយបុរសមិនប្រាកដថាស្តាប់យើងនោះទេ។ ប៉ុន្តែចំពោះការពិភាក្សាស្ត្រីជាមួយនឹងស្ត្រីដូចគ្នាវិញ វាមានលក្ខណៈងាយស្រួលជាង ដោយស្ត្រីជួបបញ្ហានៅក្នុងជីវិតរស់នៅច្រើនជាងបុរស។

## ៣-សន្និដ្ឋាន

ការចូលរួមរបស់អ្នកបោះឆ្នោតជាស្ត្រីក្នុងយុទ្ធនាការឃោសនាបោះឆ្នោត និងទៅបោះឆ្នោតមានការថយចុះនេះ ដោយសារស្ត្រីជាប់រវល់ក្នុងការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ម្យ៉ាងទៀត ដោយសារជីវភាពរបស់ស្ត្រីមានការខ្វះខាត និងនីតិវិធីបោះឆ្នោតមានលក្ខណៈសាំញ៉ាំ និងស្មុគស្មាញ ធ្វើឱ្យមានការលំបាក និងមិនមានការចាប់អារម្មណ៍ទៅបោះឆ្នោត។ អ្នកខ្លះទៀតបានបោះបង់ចោលការបោះឆ្នោត ដោយសារតែ ធ្លាប់មានបទពិសោធន៍ពីការបោះឆ្នោតកន្លងមកថា មិនបានផ្តល់ផលប្រយោជន៍អ្វីដល់ប្រជាពលរដ្ឋ ស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋនៅតែក្រដដែល ហើយការបោះឆ្នោតទៀតសោតក៏មិនអាចផ្លាស់ប្តូរអ្វីបានដែរ។

## ៤-អនុសាសន៍

គ្រប់គណបក្សនយោបាយទាំងអស់គួរចាត់វិធានការជាក់លាក់ ដើម្បីលើកស្ទួយស្ត្រីចូលរួមក្នុងនយោបាយ។ ការដាក់បេក្ខជនស្ត្រីនៅជួរលើ គួរតែដាក់បញ្ចូលនៅក្នុងគោលនយោបាយរបស់គណបក្សសំរាប់ស្ត្រី។ លើសពីនេះទៅទៀតគ្រប់ភាគីពាក់ព័ន្ធគួរតែចូលរួមឱ្យបានកាន់តែសកម្មក្នុងការលើកកំពស់ ការចូលរួមរបស់ស្ត្រីតាមរយៈការកសាងសមត្ថភាពបេក្ខជនស្ត្រី ការតស៊ូមតិជាមួយថ្នាក់ដឹកនាំសំរេចចិត្តលើគោលនយោបាយសំខាន់ៗ និងថ្នាក់ដឹកនាំគណបក្សនយោបាយគ្រប់លំដាប់ថ្នាក់សំរាប់ប្រព័ន្ធកូតា ដើម្បីកំណត់នៅក្នុងច្បាប់ និងគោលនយោបាយរបស់គណបក្ស។ សូមឱ្យមានការគាំទ្រ និងការបង្កើនកម្មវិធីយុទ្ធសាស្ត្រដូចតទៅ :

-ពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយយកចិត្តទុកដាក់ លើកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ

-ជំរុញការសិក្សាក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធរបស់ស្ត្រី / ស្ត្រីក្នុងសេដ្ឋកិច្ច /សុខភាពបន្តពូជ/ស្ត្រី និងការការពារដោយច្បាប់ និងច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ។ល។

-ពង្រឹង និងបង្កើនសមត្ថភាពដល់ស្ត្រីដើម្បីឱ្យមាននិរន្តរភាព លើផ្នែកធនធានមនុស្ស និងកម្មវិធីផ្សេងៗ ជាច្រើនទៀត។

-ផ្តល់ឱកាសឱ្យស្ត្រីបានចូលរួមយ៉ាងទូលំទូលាយក្នុងវិស័យនយោបាយ លុបបំបាត់ការរើសអើងលើស្ត្រីនៅក្នុងសង្គម ដើម្បីឱ្យស្ត្រីមានសិទ្ធិបញ្ចេញមតិក្នុងការកសាងសង្គមជាតិ និងសិទ្ធិឈរឈ្មោះបោះឆ្នោត។

## IV. សេចក្តីសន្និដ្ឋាន/អនុសាសន៍

**ការរកឃើញសំខាន់ៗមានដូចខាងក្រោម ÷**

+ ការបោះឆ្នោតអាណត្តិទី៤ ចំនួន បេក្ខជនស្ត្រីឈរឈ្មោះមានកំរិតថយចុះ ១២,២០% ( ២៧% ឆ្នាំ២០០៣ និង ១៤.៨០% ឆ្នាំ២០០៨)។ ទោះជាយ៉ាងនេះក៏ដោយ គណបក្សប្រជាជនកម្ពុជា មានបេក្ខជនស្ត្រីកើនឡើងពី ១៤នាក់ ស្មើនឹង ១១,៣៨% (២០០៣) ទៅ ២០នាក់ ស្មើនឹង ១៦,២៦% (២០០៨) និងគណបក្សសម រង្ស៊ី មានបេក្ខជនស្ត្រីកើនឡើងពី ១៥នាក់ ស្មើនឹង ១២,១៩% (២០០៣) ទៅ ១៧នាក់ ស្មើនឹង ១៣.៨២% (២០០៨)។

+ ចំនួនស្ត្រីជាប់ឆ្នោតនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ មានការកើនឡើងបន្តិចបន្តួចបើធៀបនឹងការបោះឆ្នោតមុនៗ (១៨នាក់ ស្មើនឹង ១៤,៦៣%ក្នុងឆ្នាំ២០០៨ និង ១៥នាក់ ស្មើនឹង១២,១៩% ក្នុងឆ្នាំ២០០៣ ជាប់ឆ្នោតភ្លាមៗ)។

+ ក្នុងដំណើរការយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០០៨ ចាប់ពីថ្ងៃទី២៦ ខែមិថុនា ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ មានគណបក្សនយោបាយទាំង១១ បានធ្វើសកម្មភាពឃោសនាដើម្បីបង្ហាញដល់អ្នកបោះឆ្នោតនូវគោលនយោបាយរបស់ខ្លួនដែលទាក់ទិន បញ្ហាស្ត្រី និងកុមារ ដើម្បីដោះស្រាយក្នុងអាណត្តិទី៤នេះ។

+ ចំនួនស្ត្រីរឹតតែតិចតួចថែមទៀតចំពោះគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោមៗដូចជា គណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត (គធ/ខប) និងគណៈកម្មការឃុំ/សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) និងមានចំនួនស្ត្រីតិចតួចបំផុតដែលកាន់តួនាទីក្នុងថ្នាក់សំរេចចិត្តលើការគ្រប់គ្រងការបោះឆ្នោត។

+ អ្នកសង្កេតការណ៍ស្ត្រីដែលមកពីអង្គការឯករាជ្យ គឺ មានចំនួនស្ត្រីប្រមាណ ៣៥% ច្រើនជាងភ្នាក់ងារសង្កេតការណ៍ស្ត្រីមកពីគណបក្សនយោបាយមានតែជាង ១៧%។

+ មានអ្នកបោះឆ្នោតស្ត្រីច្រើនជាងបុរសបានទៅបោះឆ្នោតនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨។

+ ទិន្នន័យ និងលទ្ធផលការស្រាវជ្រាវ ករណីសិក្សានៅខេត្តកណ្តាល តាកែវ និងកំពង់ធំ **រកឃើញ** ការចូលរួមរបស់អ្នកបោះឆ្នោតជាស្ត្រីក្នុងយុទ្ធនាការឃោសនាបោះឆ្នោត និងបានទៅបោះឆ្នោតមានការថយចុះ នេះ

ដោយសារស្ត្រីជាប់រវល់ក្នុងការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ។ ដោយសារជីវភាពមានការខ្វះខាត និងនីតិវិធីបោះឆ្នោតមានលក្ខណៈសាំញ៉ាំ និងស្មុគស្មាញ ធ្វើឱ្យមានការលំបាក និងមិនមានការចាប់អារម្មណ៍ទៅបោះឆ្នោត ស្ត្រីមួយចំនួនតូចបានបោះបង់ចោលការបោះឆ្នោត ម្យ៉ាងទៀតដោយសារតែធ្លាប់មានបទពិសោធន៍ពីការបោះឆ្នោតកន្លងមកថា មិនបានផ្តល់ផលប្រយោជន៍អ្វីដល់ប្រជាពលរដ្ឋ ស្ថានភាពជីវភាពរបស់ប្រជាពលរដ្ឋនៅតែក្រដដែល ហើយការបោះឆ្នោតទៀតសោតក៏មិនអាចផ្លាស់ប្តូរអ្វីបានដែរ ។

ដើម្បីលើកកំពស់សមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រីវិធានការមួយចំនួនគួរតែដោះស្រាយដូចជា ÷

**១. គោលនយោបាយរបស់គណបក្ស និងប្រព័ន្ធកូតា**

ត្រូវផ្តល់ឱកាសចំពោះស្ត្រី និងលុបបំបាត់នូវរាល់ទម្រង់នៃការរើងអើងទាំងឡាយ ដើម្បីលើកតំកើង និងលើកកំពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ យើងចាំបាច់ត្រូវផ្តល់នូវធម្មនុញ្ញភាពសំរាប់ប្រព័ន្ធកូតា។ នៅក្នុងច្បាប់បោះឆ្នោត និងគោលនយោបាយរបស់គណបក្សនយោបាយត្រូវមានកំណត់ផងដែរពីកូតា និងធ្វើយ៉ាងណាជំរុញការអនុវត្តក្របខណ្ឌច្បាប់ទាំងនេះ។ យ៉ាងហោចណាស់ក៏ត្រូវមានបេក្ខជនស្ត្រី៣០%ជាបេក្ខជនពេញសិទ្ធិ ហើយត្រូវចែងនៅក្នុងច្បាប់បោះឆ្នោត។ យ៉ាងណាក៏ដោយចាំបាច់ត្រូវមានការគាំទ្រពីស្ត្រីចំពោះការឈរឈ្មោះរបស់បេក្ខជនជាស្ត្រី និងជំរុញនូវយុទ្ធនាការជាសាធារណៈពីសារៈសំខាន់នៃប្រព័ន្ធកូតា ដើម្បីធានាកំណើននៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ។

**២. ការកសាងសមត្ថភាពសំរាប់បេក្ខជនស្ត្រី**

ចាំបាច់ត្រូវមានការកំណត់ និងលើកឡើងពីសក្តានុពលភាពចំពោះបេក្ខជនស្ត្រី/អ្នកនយោបាយជាស្ត្រីសំរាប់ផ្តល់វគ្គហ្វឹកហ្វឺនខ្លីៗសំរាប់មុនពេល និងក្រោយពេលបោះឆ្នោតដល់បេក្ខជនស្ត្រី ដើម្បីបង្កើនការជឿជាក់ និងប្រសិទ្ធភាពបំរើការក្នុងការិយាល័យរបស់ស្ត្រីនៅពេលជាប់ឆ្នោត។ ជាងនេះទៅទៀត ត្រូវមានការរៀបចំ និងបណ្តុះបណ្តាលដល់អ្នកដឹកនាំជាស្ត្រីដែលមានសក្តានុពល និងបេក្ខជនស្ត្រីជំនាន់ក្រោយទៀត។ ត្រូវរៀបចំឱ្យមាន និងការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល ហ្វឹកហ្វឺនគ្រូបង្គោលនៅក្នុងគណបក្សនយោបាយ ដើម្បីពង្រីកចំណេះដឹង និងសមត្ថភាពពួកគេ។

**៣. ការអប់រំអ្នកបោះឆ្នោត**

គ.ជ.ប និងអង្គការសង្គមស៊ីវិល ត្រូវតែយកចិត្តទុកដាក់បន្ថែមទៀតចំពោះការអប់រំប្រជាពលរដ្ឋ ជាពិសេសអប់រំអ្នកបោះឆ្នោតមុនពេលចុះឈ្មោះ និងធ្វើបច្ចុប្បន្នភាពបញ្ជីអ្នកបោះឆ្នោតក្នុងដំណើរការបោះឆ្នោតទាំងនៅទីក្រុង និងជនបទដាច់ស្រយាល។ អ្នកពាក់ព័ន្ធទាំងនេះគួរតែ

ធ្វើការសហការជាមួយអង្គការសង្គមស៊ីវិលដូចជាសហគមន៍ អង្គការអភិវឌ្ឍន៍តាមមូលដ្ឋាន ដើម្បីពង្រីកការផ្សព្វផ្សាយអប់រំរបស់ខ្លួនឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព។ ធ្វើដូច្នេះ ព័ត៌មានទាំងឡាយអំពី ការបោះឆ្នោតនឹងមានការជ្រួតជ្រាបដល់អ្នកបោះឆ្នោតនៅតាមចុងកាត់មាត់ញក (តំបន់ដាច់ស្រយាល) ហើយពួកគេនឹងមានលទ្ធភាពបោះឆ្នោតបានត្រឹមត្រូវ។

ស្ថាប័នរដ្ឋាភិបាល ក្នុងនោះរួមទាំងគ.ជ.ប និង អង្គការសង្គមស៊ីវិល គួរតែផ្តល់អាទិភាពចំពោះគំនិតផ្តួចផ្តើមសំរាប់ការអប់រំអ្នកបោះឆ្នោត (ពលរដ្ឋ)ដែលមានលក្ខណៈទូលំទូលាយ និងកំណត់គោលដៅច្បាស់លាស់ ដោយពិចារណាទៅលើអត្តរកម្មទាបនៅក្នុងប្រទេសកម្ពុជា។ គំនិតផ្តួចផ្តើមនេះអាចដាក់ទៅក្នុងកម្មវិធីសិក្សាដែលផ្តល់ដោយគ្រឹះស្ថានអប់រំរដ្ឋ និងឯកជននៅគ្រប់កំរិត។

## ៤. ប្រព័ន្ធផ្សព្វផ្សាយ

ចាំបាច់ត្រូវមានការចូលរួម និងចែករំលែកព័ត៌មានយ៉ាងល្អជាមួយនឹងសហគមន៍មូលដ្ឋានទាក់ទងនឹងតួនាទីរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ ការបំពេញភារកិច្ច និងសមិទ្ធិផលដែលពួកគេសំរេចបានមុន និងក្នុងពេលដែលស្ត្រីបំពេញការងារក្នុងការិយាល័យ ការសំរេចចិត្ត និងការគ្រប់គ្រង់ ចាត់ចែងធនធានជាដើម។ សេចក្តីត្រូវការផ្សេងទៀតគឺបង្កើនប្រសិទ្ធភាពបញ្ជូនព័ត៌មាន និងធ្វើការអប់រំប្រជាពលរដ្ឋមូលដ្ឋានអំពីតួនាទីរបស់ក្រុមប្រឹក្សាដែលបានបោះឆ្នោតដោយប្រជាពលរដ្ឋ ការទទួលខុសត្រូវ និងអាណត្តិ (អំណាចចាត់ចែងការងារដែលច្បាប់ប្រគល់ឱ្យ)របស់ពួកគេ។ ធ្វើដូចនេះប្រជាពលរដ្ឋនឹងមានការយល់ដឹងកាន់តែច្បាស់ពីឥទ្ធិពលនៃបេក្ខភាពស្ត្រី។ ម្យ៉ាងទៀត ព័ត៌មានត្រូវតែមានលក្ខណៈងាយស្រួលក្នុងការទទួលបានសំរាប់ប្រជាពលរដ្ឋមូលដ្ឋានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។